លេខ ១០ ខែតុលា ឆ្នាំ ១៩៩០

# រដ្ឋកិច្ច

រួមមាន :

- ច្បាប់
- ក្រឹត្យ-ច្បាប់
- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ
- សារាចរណែនាំ

ផ្សាយចេញពីខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ជារៀងរាល់ខែ

Downloaded from http://www.khmerlaws.com

# មាតិកា

## I – ក្រុមប្រឹក្សារដ្ឋ

### ១ – ក្រឹត្យ

០៣-១០-១៩៩០ ក្រឹត្យលេខ ៥៦ ក្រ ស្ដីពីការផ្ទេរភារកិច្ច សមមិត្ត ស៊ុខ ផល ២៥៥

០៣-១០-១៩៩០ ក្រឹត្យលេខ ៥៧ ក្រ ស្ដីពីការផ្ទេរភារកិច្ចសមមិត្តឧត្ដមសេនីយត្រី ប៉ែន ពាត ២៥៦

០៥-១០-១៩៩០ ក្រឹត្យលេខ ៦១ ក្រ ស្ដីពីការតែងតាំងសមមិត្ត អ៊ុក រ៉ាប៊ុន ជាអនុរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ២៥៧

១៩-១០-១៩៩០ ក្រឹត្យលេខ ៦៣ ក្រ ស្ដីពីការរំសាយសមមិត្ត មាស ស៊ុប ពីឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃរដ្ឋកម្ពុជាប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យ អាល្លឺម៉ង់ ២៥៨

២៧-១០-១៩៩០ ក្រឹត្យលេខ ៦៥ ក្រ ស្ដីពីការតែងតាំងសមមិត្ត ឧត្ដមសេនីយត្រី ឃឹម ប៊ុណ្ណ ជាអគ្គរដ្ឋអាជ្ញារងនៃមហាអយ្យការ អមតុលាការកំពូល ២៥៩

## II – ក្រុមប្រឹក្សារដ្ឋមន្ត្រី

### ១ – សេចក្ដីសំរេច

១០-១០-១៩៩០ សេចក្ដីសំរេចលេខ ១៤៣ សសរ ស្ដីពីប្រាក់ឧបត្ថម្ភ ថ្លៃអង្ករជូនកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ២៦០

១០-១០-១៩៩០ សេចក្ដីសំរេចលេខ ១៤៤ សសរ ស្ដីពីថ្លៃទិញស្រូវ ឆ្នាំ ១៩៩០-១៩៩១ ២៦២

១២-១០-១៩៩០ សេចក្ដីសំរេចលេខ ១៤៥ សសរ ស្ដីពីអាហារូបករណ៍ និងរបបឧបត្ថម្ភដល់ភោជ អន្តេវាសិក ២៦៣

១៣-១០-១៩៩០ សេចក្ដីសំរេចលេខ ១៤៦ សសរ ស្ដីពីការបង្កើតមេឡារៀងសំរាប់ទ្រទ្រង់សមរភូមិមុខ ២៦៧

២៥-១០-១៩៩០ សេចក្ដីសំរេចលេខ ១៥២ សសរ ស្ដីពីការបង្កើតរោងភាពជាតិ ២៦៩

Downloaded from http://www.khmerlaws.com

# III - ការចារបណ្ណាក្រសួង

## ១ - ក្រសួងហិរញ្ញវត្ថុ

### ប្រកាស


០៨ - ១០ - ១៩៩០ ប្រកាសលេខ ៨១០ កហរ ស្តីពីការកែប្រែបំពេញបន្ថែម និងកំណត់ជាប័ន្ទាវថ្លៃគិតពន្ធលើទំនិញ នាំចេញ និង នាំចូល ២៨០

០៨ - ១០ - ១៩៩០ ប្រកាសលេខ ០១១ កហរ ស្តីពីការបន្ធូរបន្ថយប្រាក់ពន្ធលើទំនិញនាំចូល ចំពោះមុខទំនិញដែលជាប់អត្រាពន្ធខ្ពស់ ២៨១


### អន្តរក្រសួង

### ក្រសួងហិរញ្ញវត្ថុ ធនាគារជាតិកម្ពុជា

### សេចក្តីណែនាំ


១៦ - ១០ - ១៩៩០ សេចក្តីណែនាំលេខ ធ ៩៩០.០០១ សណន ស្តីពីការធ្វើអាជីវកម្ម ឬ ដូរប្រាក់ និងទិញ-លក់លោហធាតុ ត្បូងថ្មមានតម្លៃ ២៨៣


Downloaded from http://www.khmerlaws.com

# I – ក្រុមប្រឹក្សារដ្ឋ

## ខ – ក្រឹត្យ

## ក្រឹត្យលេខ ៥៦ ក្រ

## ក្រុមប្រឹក្សារដ្ឋ

## នៃរដ្ឋកម្ពុជា

– បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញច្បាប់ ស្តីពីការបង្កើតតុលាការប្រជាជនកំពូល និង មហាអយ្យការអមតុលាការប្រជាជនកំពូល ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៨៥

– បានឃើញក្រឹត្យ. ច្បាប់លេខ ៣៤ ក្រ.ច ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៨៨ ស្តីពីការចាត់តាំង និង សកម្មភាពរបស់តុលាការប្រជាជនកំពូល និង មហាអយ្យការអមតុលាការប្រជាជនកំពូល

– តាមសំណើរបស់តុលាការប្រជាជនកំពូល

## សំរេច

*មាត្រា ១*.- ត្រូវបានផ្ទេរសមមិត្ត *សុខ ឌួន* ពីចៅក្រមតុលាការប្រជាជនកំពូល អោយទៅបំរើការងារនៅក្រសួងមហាផ្ទៃវិញ ។

Downloaded from http://www.khmerlaws.com

*មាត្រា ២* . — ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

*ភ្នំពេញ ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩០*

ជ. ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

# ក្រឹត្យលេខ ៥៧ ក្រ

## ក្រុមប្រឹក្សារដ្ឋ

## នៃរដ្ឋកម្ពុជា

— បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

— បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

### សំរេច

*មាត្រា ១* . — ត្រូវបានផ្ទេរភារកិច្ច សមមិត្ត ឧត្តមសេនីយត្រី *បើង ប៉ាត់* ពីអនុរដ្ឋមន្ត្រីក្រសួងការពារប្រទេស អោយទៅទទួលជាអនុរដ្ឋមន្ត្រីក្រសួងកសិកម្ម ដោយរក្សាទុកឋានន្តរស័ក្តិនោដដែល ។

*មាត្រា ២* . — ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

*ធ្វើនៅភ្នំពេញ ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩០*

ជ. ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

Downloaded from http://www.khmerlaws.com

# ក្រឹត្យ លេខ ៦១ ក្រ

## *ក្រុមប្រឹក្សារដ្ឋ*

## នៃ

## រដ្ឋកម្ពុជា

– បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញច្បាប់ស្តីអំពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

## សំរេច

*មាត្រា ១* .– ត្រូវបានតែងតាំងជាអនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សមមិត្ត *អ៊ុក រ៉ាប៊ុន* បច្ចុប្បន្នអនុប្រធានខុទ្ទកាល័យមជ្ឈិមបក្ស ។

*មាត្រា ២* .– ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

*ធ្វើនៅភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩០*

ជ . ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

Downloaded from http://www.khmerlaws.com

# ក្រឹត្យលេខ ៦៣ ក្រ

## ក្រុមប្រឹក្សារដ្ឋ

## នៃ

## រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- បានឃើញច្បាប់ ស្តីអំពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

### សំរេច

*មាត្រា ១* .- ត្រូវបានរំសាយសមមិត្ត *ខាស ស៊ិម* ពីឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃរដ្ឋកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ដោយនៅជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និង ពេញសមត្ថភាពនៃរដ្ឋកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតសង្គមនិយមអាល់បានី សាធារណរដ្ឋប្រជាមានិតអង់ហ្គោឡា សាធារណរដ្ឋប្រជាមានិតកុងហ្គោ សាធារណរដ្ឋប្រជាមានិតបេណាំង និង អង្គការប្រជាជនអាហ្វ្រិកនិរតី " ណាមីប៊ី " ។

*មាត្រា ២* .- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

*ធ្វើនៅភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩០*

ជ. ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

Downloaded from http://www.khmerlaws.com

# ក្រឹត្យលេខ ៦៥ ក្រ

## ក្រុមប្រឹក្សារដ្ឋ

## នៃរដ្ឋកម្ពុជា

— បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

— បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញច្បាប់ ស្តីអំពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញច្បាប់ ស្តីពីការបង្កើតតុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ២៩ ក្រ ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ១៩៨៥

— បានឃើញក្រឹត្យ - ច្បាប់លេខ ៣៤ ក្រ·ច ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ១៩៨៨ ស្តីពីការចាត់តាំង និង សកម្មភាពរបស់តុលាការប្រជាជនកំពូល និង មហាអយ្យការអមតុលាការប្រជាជនកំពូល

— តាមសំណើរបស់អគ្គរដ្ឋអាជ្ញាអមតុលាការប្រជាជនកំពូល

## សំរេច

*មាត្រា ១* .— ត្រូវបានតែងតាំងជា អគ្គរដ្ឋអាជ្ញារង នៃមហាអយ្យការអមតុលាការប្រជាជនកំពូល ដែលមានឋានៈស្មើរដ្ឋមន្ត្រី សមមិត្តឧត្តមសេនីយ៍ត្រី ឃឹម ប៊ុណ្ណ បច្ចុប្បន្នអនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

*មាត្រា ២* .— ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ ខុទ្ទកាល័យ ក្រុមប្រឹក្សារដ្ឋមន្ត្រី មហាអយ្យការអមតុលាការប្រជាជនកំពូល ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

*ធ្វើនៅភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩០*

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

Downloaded from http://www.khmerlaws.com

# ក - ក្រុមប្រឹក្សារដ្ឋមន្ត្រី

## ១ - សេចក្តីសំរេច

*ភ្នំពេញ, ថ្ងៃទី១០ ខែ តុលា ឆ្នាំ ១៩៩០*

### សេចក្តីសំរេច លេខ ១៤៣ សសរ

### ស្តីពី

### ប្រាក់ឧបត្ថម្ភថ្លៃអង្ករជូនកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ

### ក្រុមប្រឹក្សារដ្ឋមន្ត្រី

– បានឃើញរដ្ឋធម្មនុញ្ញរដ្ឋកម្ពុជា

– បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញសេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ១៣០ សសរ ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៨៧ ស្តីពីការដោះស្រាយជីវភាពរបស់កម្មាភិបាល បុគ្គលិក កម្មករ

– បានឃើញសេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ៧៣ សសរ ចុះថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ១៩៩០ ស្តីពីប្រាក់ឧបត្ថម្ភលើប្រាក់បៀវត្ស និង ប្រាក់សោធនជូនដល់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និង និវត្តជន និង ជនបាត់បង់សមត្ថភាពពលកម្ម

– តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

### សំរេច

*ប្រការ ១* : បទបញ្ញត្តិប្រការ ៣ នៃសេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ៧៣ សសរ ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៩០ ត្រូវបានកែសំរួលដូចតទៅ :

– ថ្លៃអង្ករសំរាប់ផ្តល់ជំនួសរបបអង្កររបស់កម្មាភិបាល បុគ្គលិក កម្មករនៃចំណុច "ក" "ខ" "គ" ត្រូវកំណត់ ៧០ រ ០០ " ចិតសិបរៀលគត់ " ក្នុង ១ គីឡូក្រាម ។

– ប្រាក់ថ្លៃអង្ករខាងលើនេះ ជាថ្លៃដោយឡែកដើម្បីគិតជាប្រាក់ឧបត្ថម្ភបញ្ចូលក្នុងបៀវត្សពោលគឺពុំមែនជាថ្លៃធ្វើអាជីវកម្មអង្កររបស់ក្រសួងពាណិជ្ជកម្ម ឬ ផ្នែកពាណិជ្ជកម្មនានានោះទេ ។

– ខេត្តមួយចំនួនដូចជាខេត្តកំពង់ចាមជាដើមដែលបានប្រាក់លំអៀងថ្លៃអង្ករជូនកម្មាភិបាល

Downloaded from http://www.khmerlaws.com

បុគ្គលិក កម្មករ សំរាប់ទិញអង្ករបេបមួយឆ្នាំ ឆ្នាំ១៩៩០ រួចហើយនោះមិនត្រូវយកថ្លៃអង្ករថ្មីនេះទៅគិតដើម្បីផ្តល់ប្រាក់លំអៀងថ្លៃបន្ថែមទៀតទេ ។

*ប្រការ២* : ក្រសួងផែនការ ត្រូវតាមដានជាប្រចាំថ្ងៃអង្ករនៅលើទីផ្សាររដ្ឋធានីភ្នំពេញ និងខេត្តចំនួន ៥ ទៀតគឺ ខេត្តស្វាយរៀង តាកែវ កំពង់ចាម បាត់ដំបង និង សៀមរាបឧត្តរមានជ័យ ដើម្បីធ្វើជាមូលដ្ឋានសំរាប់គិតវិសេមភាពថ្លៃអង្ករ ។ ពេលណាថ្លៃអង្ករលេខ ២ ឡើងលើសពី ១០ ភាគរយ ក្រសួងផែនការត្រូវប្រកាសផ្សាយបរិមាណទឹកប្រាក់ដែលត្រូវបន្ថែមទៅក្នុងបៀវត្សតាមសមាមាត្រកំណើននោះ ។

*ប្រការ៣* : បណ្តាខេត្ត ក្រុងត្រូវមានវិធានការម៉ឺងម៉ាត់ក្នុងការទប់ស្កាត់ការហូរចេញស្រូវអង្ករពុំស្របច្បាប់តាមច្រកព្រំដែន និង ត្រូវជួយបង្កលក្ខណៈ អោយក្រសួងពាណិជ្ជកម្ម និងបណ្តាអង្គភាពដែលមានភារកិច្ចប្រមូលទិញស្រូវ អង្ករជូនរដ្ឋទទួលបានលទ្ធផលល្អសំដៅធានាបរិមាណស្រូវ អង្ករគ្រប់គ្រាន់សំរាប់បំរើតម្រូវការប្រើប្រាស់ និង ដើម្បីធានាស្ថេរភាពថ្លៃអង្ករនៅទីផ្សារក្នុងប្រទេស ។

*ប្រការ៤* : បទបញ្ញត្តិទាំងឡាយណា ដែលមានពីមុនហើយមានន័យផ្ទុយពីសេចក្តីសំរេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

*ប្រការ៥* : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័នជុំវិញរដ្ឋមន្ត្រី និង គណៈកម្មាធិការប្រជាជនខេត្ត ក្រុង មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ។

សេចក្តីសំរេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីខែ កញ្ញា ឆ្នាំ ១៩៩០ តទៅ ។

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី
អនុប្រធាន
ហត្ថលេខា និង ត្រា
ជា សុទ្ធ

Downloaded from http://www.khmerlaws.com

*ភ្នំពេញ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩០*

# សេចក្តីសំរេចលេខ ១៤៤ សសរ
# ស្តីពីថ្លៃទិញស្រូវ ឆ្នាំ ១៩៩០_៩១

## *ក្រុមប្រឹក្សារដ្ឋមន្ត្រី*

- បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ.ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- យោងការសំរេចរបស់គណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សារដ្ឋមន្ត្រីនាថ្ងៃទី ០៨ ខែ តុលា ឆ្នាំ១៩៩០
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សំរេច

*ប្រការ ១* : កំណត់ថ្លៃទិញស្រូវហួសពីប្រជាជនតាមកំរិតថ្លៃ ៣៥រ« សាមសិបប្រាំរៀល» ក្នុងមួយគីឡូក្រាម សំរាប់អនុវត្តក្នុងទូទាំងប្រទេស ។

*ប្រការ ២* : ផ្អែកតាមកំរិតថ្លៃក្នុងប្រការ ១ ខាងលើ ក្រសួងពាណិជ្ជកម្មមានភារកិច្ចកំណត់ថ្លៃទិញស្រូវប្រភេទផ្សេងៗទៀត កំណត់អប្បហារព្រមទាំងធ្វើការណែនាំអនុវត្តជាក់ស្តែង ។

*ប្រការ ៣* : ក្រសួងកសិកម្ម មានភារកិច្ចកំណត់ថ្លៃទិញ និង ថ្លៃលក់ស្រូវពូជគ្រប់ប្រភេទ អោយបានសមស្របលើមូលដ្ឋានជំរុញផលិតកម្មស្រូវក្នុងទូទាំងប្រទេស ។

*ប្រការ ៤* : បទបញ្ញត្តិទាំងឡាយណាដែលមានពីមុនមកផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

*ប្រការ ៥* : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម ក្រសួង-កសិកម្ម ក្រសួងហិរញ្ញវត្ថុ ធនាគារជាតិកម្ពុជា និង គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង មានភារកិច្ចអនុវត្តសេចក្តីសំរេចអោយមានប្រសិទ្ធភាពខ្ពស់ ។

- សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ជា សុទ្ធ

Downloaded from http://www.khmerlaws.com

*ភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩០*

# សេចក្តីសំរេច លេខ ១៤៥ សសរ

## ស្តីពីអាហារូបករណ៍ និង របបឧបត្ថម្ភ ជីវភាព អន្តេវាសិក

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

— បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— យោងសេចក្តីសំរេចលេខ ១៦៦ សសរ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៨៨ ស្តីពីអាហារូបករណ៍សិស្សនិស្សិត និង កម្មាភិបាល បុគ្គលិក កម្មករដ្ឋ របបឧបត្ថម្ភជីវភាពអន្តេវាសិក និង ប្រាក់កំរៃ ម៉ោងបន្ថែម

— តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សំរេច

*ប្រការ ១*: កំណត់អាហារូបករណ៍ប្រចាំខែផលសិស្ស និងនិស្សិតសុទ្ធសាធដែលបានសិក្សា នៅតាមគ្រឹះស្ថានឧត្តមសិក្សានិង សិក្សាឯកទេសតាមការាងខាងក្រោមនេះ :

| *កំរិតសិក្សាឯកទេស និង មុខជំនាញ* | *កំរិតប្រាក់អាហារូបករណ៍ប្រចាំខែ* |
|---|---|
| – ក្រោយឧត្តមសិក្សា | ២.០០០៛០០ |
| – ឧត្តមសិក្សា | ១.៨០០៛០០ |
| – មធ្យមសិក្សា | ១.៧០០៛០០ |
| – បឋមសិក្សា | ១.៦០០៛០០ |

កំរិតប្រាក់អាហារូបករណ៍ខាងលើ បានគិតរួចហើយនូវប្រាក់ថ្លៃ អង្ករ ចំនួន ១៨ គ.ក្រ ក្នុង ១ ខែ ។

អាហារូបករណ៍នេះ អនុវត្តតែក្នុងរយៈពេលដែលសិស្ស និស្សិតកំពុងសិក្សា ដោយគោរពវិន័យបានល្អ និង ខិតខំប្រឹងប្រែងរៀនសូត្របានលទ្ធផលល្អ ។

Downloaded from http://www.khmerlaws.com

*ប្រការ ២* : កំណត់ប្រាក់បំប៉នប្រចាំខែ បន្ថែមជូនសិស្ស និស្សិតសុទ្ធសាធផ្នែកកីឡាសៀក ទៅទៀតប្រាក់ចំនួន ២០ ភាគរយ លើកំរិតប្រាក់អាហារូបករណ៍ដែលមានចែងក្នុងប្រការទី ១ ខាងលើ ។

*ប្រការ ៣* : ចំនួនសិស្ស និស្សិតសុទ្ធសាធដែលត្រូវទទួលអាហារូបករណ៍ ត្រូវកំណត់ដូចតទៅ :

ក - សាលាគរុកោសល្យភូមិភាគ សាលាគរុកោសល្យខេត្ត ក្រុង ការបណ្តុះបណ្តាលសាស្ត្រាចារ្យនិងគ្រូបង្រៀននៅសកលវិទ្យាល័យភ្នំពេញ និងការបណ្តុះបណ្តាលផ្នែកសៀក ត្រូវបានទទួលអាហារូបករណ៍ ១០០ ភាគរយលើចំនួនសិស្ស និស្សិតសុទ្ធសាធសរុប ។

ខ - សិស្ស និស្សិតសុទ្ធសាធដែលរៀនក្នុងគ្រឹះស្ថានសិក្សាឯកទេស និងមុខជំនាញដទៃទៀតហើយបានចុះកិច្ចសន្យាស្ម័គ្រចិត្តធ្វើគ្រូបង្រៀនក្រោយពេលរៀនចប់ ត្រូវបានទទួលអាហារូបករណ៍ជាស្វ័យប្រវត្តិទៅតាមចំនួនជាក់ស្តែងនៃឆ្នាំនីមួយៗ ដែលកំណត់ដោយប្រកាសរបស់ក្រសួងអប់រំ ។

គ្រឹះស្ថានសិក្សាឯកទេស និងមុខជំនាញផ្សេងៗ ទៀតត្រូវកំណត់ចំនួនសិស្ស និស្សិតទទួលអាហារូបករណ៍តាមចំនួនភាគរយ ដូចមានក្នុងតារាងខាងក្រោមនេះ :

| កំរិតសិក្សាឯកទេស និងមុខជំនាញ | កំរិតកំណត់អាហារូបករណ៍ |
|---|---|
| – ក្រោយឧត្តមសិក្សា | ១០០ ភាគរយ |
| – ឧត្តមសិក្សា | ៣០ ភាគរយ |
| – មធ្យមសិក្សា | ២០ ភាគរយ |
| – បឋមសិក្សា | ១០ ភាគរយ |

គ — កំរិតកំណត់អាហារូបករណ៍នៃចំណុច ខ ខាងលើគិតលើចំនួនសិស្ស និស្សិតសុទ្ធសាធដែលនៅសល់ពីការស្ម័គ្រចិត្តធ្វើគ្រូ ។

ឃ - ការកំណត់ចំនួនសិស្ស និស្សិតសុទ្ធសាធដែលត្រូវបានទទួលអាហារូបករណ៍ និងការអនុវត្តន៍លក្ខខណ្ឌក្នុងការផ្តល់អាហារូបករណ៍របស់សិស្ស និស្សិតសុទ្ធសាធត្រូវធ្វើមួយឆ្នាំម្តង ផងត្រូវអនុវត្តចាប់ពីបើកសកលសិក្សាឆ្នាំ ១៩៩០ _ ៩១ តទៅ ។

*ប្រការ ៤* : – លក្ខខណ្ឌក្នុងការផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិតកំណត់ដូចតទៅ:

Downloaded from http://www.khmerlaws.com

១ — កូនរបស់យុទ្ធជន កម្មាភិបាល កម្មករ និង ពលករពលី

២ — សិស្ស និស្សិតដែលរៀនពូកែឆ្នើម

៣ — កូនរបស់យុទ្ធជន

៤ — កូនកំព្រាឪពុក និង ម្តាយ

៥ — កូនជនជាតិភាគតិចនៅតំបន់ព្រៃភ្នំដាច់ស្រយាល

៦ — កូនកសិករក្រ

៧ — កូនកម្មាភិបាល បុគ្គលិក កម្មកររដ្ឋដែលឪពុក ម្តាយមានជីវភាពរស់នៅជួបការ លំបាកពិតប្រាកដ ។

*ប្រការ ៥* : កំណត់របបឧបត្ថម្ភជីវភាព ក្នុងអន្តេវាសិកដ្ឋានប្រចាំថ្ងៃដល់សិក្ខាកាម គ្រប់ប្រភេទដែលស្ថាប័នមានសមត្ថកិច្ចអនុញ្ញាតអោយទៅសិក្សា ធ្វើកម្មសិក្សា ស្ញើតការ ឬ ចំប៉ិនមុខជំនាញផ្សេង ៗ នូវទឹកប្រាក់ប្រចាំថ្ងៃ ដូចខាងក្រោមនេះ :

| ទីកន្លែងសិក្សា | រយៈពេលសិក្សា | *ប្រាក់ឧបត្ថម្ភជីវភាពប្រចាំថ្ងៃ អន្តេវាសិក* | *របបអង្ករប្រចាំខែ គិតតាមថ្លៃសាធារណៈ របស់ក្រសួងពាណិជ្ជកម្ម* |
|---|---|---|---|
| - សាលានយោបាយមជ្ឈិម | រយៈពេលកំណត់ ដោយស្ថាប័នគ្រប់គ្រង | ៨០% | ២១ គ.ក្រ |
| - រដ្ឋធានីភ្នំពេញ | តិចជាង ១២ ខែ | ៨០% | ១៨ គ.ក្រ |
| - ភូមិភាគឥសាន | តិចជាង ១២ ខែ | ៨០% | ១៨ គ.ក្រ |
| - ខេត្ត- ក្រុង | តិចជាង ១២ ខែ | ៨០% | ១៨ គ.ក្រ |
| - ស្រុក | តិចជាង ១២ ខែ | ៦០% | ១៨ គ.ក្រ |
| - សាលាជាន់ខ្ពស់កម្មាភិបាល គ្រប់គ្រងអប់រំ | | | |
| - សាលាចំពេញវិជ្ជាមជ្ឈិម | រយៈពេលកំណត់ | | |
| - សាលាចំពេញវិជ្ជារៀបរយ ភូមិភាគស្ទឹងត្រែង | ដោយស្ថាប័នគ្រប់គ្រងសាលាទាំងអស់ | ៨០% | ១៨ គ.ក្រ |
| - សាលាចំពេញវិជ្ជារៀបរយខេត្ត | | | |

Downloaded from http://www.khmerlaws.com

ព្រះវិហារ រតនគិរី មណ្ឌលគិរី
និងកោះកុង

- សាលាគរុកោសល្យភូមិភាគ
ឥសាន

*ប្រការ ៦ :* ក្រសួងហិរញ្ញវត្ថុ ត្រូវផ្តល់ប្រាក់បន្ថែមលើអាហារូបករណ៍ប្រចាំខែ និងប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ ជូនដល់អាហារូបករណ៍ទាំងឡាយ ដែលមានចែងក្នុងប្រការ ១ និង ប្រការ ៥ ខាងលើនៅពេលណាដែលថ្លៃអាជីវកម្មអង្ករបស់ក្រសួងពាណិជ្ជកម្មឡើងលើស ពី ១០ ភាគរយ ដោយគិតចាប់ពីថ្ងៃចេញសេចក្តីសំរេចនេះ ។

– ក្រសួងពាណិជ្ជកម្ម មានភារកិច្ចលក់អង្ករបបប្រចាំខែ តាមថ្លៃធានាអាជីវកម្មជូនដល់សាលាគរុកោសល្យទាំងអស់ដែលមានអន្តេវាសិកដ្ឋាននៅទីក្រុងភ្នំពេញ ក្នុងករណីដែលសាលាទាំងនោះមានសំណូមពរ ។

– ក្រសួងអប់រំមានភារកិច្ចណែនាំ អនុវត្តសេចក្តីសំរេចនេះ ពិសេសលើរាល់លក្ខខ័ណ្ឌក្នុងការផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិតសុខាភិបាលដែលមានចែងក្នុងប្រការ ៤ ។

*ប្រការ ៧ :* សេចក្តីសំរេចលេខ ១៦៦ សសរ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៨៧ និងបទបញ្ញត្តិទាំងឡាយពីមុនដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

*ប្រការ ៨ :* ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងហិរញ្ញវត្ថុ ក្រសួងអប់រំ ក្រសួងសុខាភិបាល និង វប្បធម៌ គ្រប់ស្ថាប័នពាក់ព័ន្ធ និង គណៈកម្មាធិការប្រជាជនគ្រប់ខេត្ត ក្រុង ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀង ៗ ខ្លួន អោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី
អនុប្រធាន
ហត្ថលេខា និង ត្រា
ជា សុទ្ធ

Downloaded from http://www.khmerlaws.com

ភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩០

# សេចក្តីសំរេច លេខ ១៤៦ សសរ

## ស្តីពីការបង្កើតបេឡាស្បៀងសំរាប់ទ្រទ្រង់សមរភូមិមុខ

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

– បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

– បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ . ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញលិខិតគណៈលេខាធិការដ្ឋានបក្សលេខ ៨៤៩ លខមឈ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ១៩៩០

– ពិនិត្យសំណូមពរចាំបាច់ និង បន្ទាន់ចំពោះមុខ

### សំរេច

*ប្រការ ១* : បង្កើតបេឡាស្បៀងសំរាប់ទ្រទ្រង់សមរភូមិមុខ តាមរយៈការជួយឧបត្ថម្ភពីគ្រប់មជ្ឈដ្ឋាន ក្នុងនោះមានការកាត់បន្ថយស្បៀងមួយភាគតូចពីរបបប្រចាំខែរបស់ កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ សំដៅបំពេញទិសស្លោក " អ្វីៗទាំងអស់ដើម្បីបំរើសមរភូមិប្រយុទ្ធ " ។

*ប្រការ ២* : អង្ករត្រូវបានកាត់បន្ថយក្នុង ១ ខែ ចំនួន :

– មួយគីឡូក្រាមក្នុង ១ នាក់ ចំពោះកម្មាភិបាល បុគ្គលិក កម្មកររដ្ឋដែលនៅទទួលរបបអង្ករ ។

– ទឹកប្រាក់ស្មើនឹងថ្លៃអង្ករមួយគីឡូក្រាម ចំពោះកម្មាភិបាល បុគ្គលិក កម្មកររដ្ឋដែលទទួលប្រាក់ជំនួសរបបអង្ករ ។

– ចំពោះប្រជាជនទូទៅ " ពាណិជ្ជករ . . . " បំផុសចលនាអោយគេទិញប័ណ្ណឧបត្ថម្ភសមរភូមិមុខ ។

– ប័ណ្ណឧបត្ថម្ភសមរភូមិមុខ គឺត្រូវចេញដោយប្រធានគណៈកម្មាធិការខេត្ត - ក្រុង ។

*ប្រការ ៣* : ប្រធានគ្រប់ក្រសួង ស្ថាប័នថ្នាក់មជ្ឈិម និង គ្រប់ខេត្ត - ក្រុង ត្រូវចាត់តាំងផ្នែកមួយដើម្បី :

Downloaded from http://www.khmerlaws.com

– គ្រប់គ្រង ថែរក្សា ទុកដាក់អោយបានហ្មត់ចត់នូវបរិមាណអង្ករដែលប្រមូលបាន
– បង្វែរសាច់ប្រាក់ដែលប្រមូលបាន ទៅទិញជាអង្ករ ឬ ទំនិញឧបភោគ - បរិភោគផ្សេងៗ តាមតម្រូវការចាំបាច់ដោយមិនត្រូវតំកល់លុយទុកឡើយ ។
– រាយការណ៍ជាទៀងរាល់ខែ ជូនក្រុមប្រឹក្សារដ្ឋមន្ត្រី ពីបរិមាណស្បៀង និងយថាប្រភេទទំនិញផ្សេងៗដែលទទួលបាន ។

ចំពោះខេត្ត - ក្រុង ក្នុងករណីចាំបាច់ និង បន្ទាន់ អាចដកមួយចំណែកពីសន្និធិស្បៀងដែលប្រមូលបាន ដើម្បីផ្គត់ផ្គង់ជូនកងកម្លាំងប្រដាប់អាវុធរបស់មូលដ្ឋានខ្លួន ដែលឈរជើងនៅសមរភូមិមុខ តែក៏ត្រូវរាយការណ៍ជូនក្រុមប្រឹក្សារដ្ឋមន្ត្រីជ្រាបដែរ ។

*ប្រការ ៤* : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី គ្រប់ក្រសួង - ស្ថាប័នជុំវិញមជ្ឈិម និង គណៈកម្មាធិការប្រជាជនគ្រប់ខេត្ត ក្រុង ត្រូវបំផុសចលនាសន្សំសំចៃនេះអោយបានខ្លាំងក្លា ដោយអនុវត្តតាមស្មារតីសេចក្តីណែនាំរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ០២ សណន.ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៨០ ដើម្បីបង្កើតប្រភពស្បៀងសំរាប់ផ្គត់ផ្គង់ជូនសមរភូមិប្រយុទ្ធនិង ត្រូវរួសរាន់ចាត់តាំងអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី
អនុប្រធាន
ហត្ថលេខា និង ត្រា
ចា ស៊ុម

Downloaded from http://www.khmerlaws.com

*ភ្នំពេញ, ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩០*

## សេចក្តីសំរេច លេខ ១៥២ សសរ

## ស្តីពី ការបង្កើតឆ្នោតជាតិ

– បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

– បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងហិរញ្ញវត្ថុ

– តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

## សំរេច

*ប្រការ ១* : បង្កើតឆ្នោតជាតិមួយដែលមានឡូតិ៍ត្រូវបានរង្វាន់ជាប្រាក់រៀល នឹងត្រូវចេញមួយលើក ក្នុងមួយខែ ។

*ប្រការ ២* : កំរៃដែលបានមកពីឆ្នោតជាតិនេះ ត្រូវទុកសំរាប់ធ្វើហិរញ្ញប្បទាន ជាគុណប្រយោជន៍ដល់ការអនុវត្តន៍គោលដៅសេដ្ឋកិច្ច - សង្គម ។

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ មានភារៈគ្រប់គ្រងកំរៃដែលបានមកពីឆ្នោតជាតិនេះ ដោយដាក់ទុកក្នុងគណនីពិសេស បើកនៅរតនាគារជាតិ ។

*ប្រការ ៣* : ក្រសួងហិរញ្ញវត្ថុ មានភារកិច្ចចេញសេចក្តីប្រកាសស្តីពីការប្រព្រឹត្តទៅ និងរបៀបចាត់គ្រប់គ្រងឆ្នោតជាតិនេះ ។

*ប្រការ ៤* : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី , ក្រសួងហិរញ្ញវត្ថុ , ធនាគារជាតិនៃប្រជាជនកម្ពុជា គ្រប់ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការប្រជាជនខេត្ត - ក្រុង ត្រូវទទួលអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ឌា សុខ

Downloaded from http://www.khmerlaws.com

# III - ការងារបណ្ដាក្រសួង

ភ្នំពេញ ថ្ងៃទី ០៨ ខែតុលា ឆ្នាំ ១៩៩០

## ១ - ក្រសួងហិរញ្ញវត្ថុ

## ប្រកាស

## ប្រកាសលេខ ០១០ កហវ.

## ស្ដីពីការកែប្រែបំពេញបន្ថែម និងកំណត់ជាថ្មី
## នូវថ្លៃគិតពន្ធលើទំនិញនាំចេញ_និងនាំចូល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្ដីពីការកែប្រែ ការចាត់តាំងតួនាទីនិងភារកិច្ចរបស់ក្រសួងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៤៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញច្បាប់ស្ដីពី ពន្ធលើទំនិញនាំចេញ និងនាំចូលដែលប្រកាសអោយប្រើដោយ ក្រឹត្យលេខ ៤៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ ។

### កំណត់

*ប្រការ ១* : យោងទៅតាមសភាពការណ៍បច្ចុប្បន្ននិងទៅតាមថ្លៃទំនិញនៅលើទីផ្សារដែលមានការកើនឡើងជាលំដាប់ ដូចនេះដើម្បីអនុវត្តកិច្ចការគ្រប់គ្រងប្រមូលពន្ធលើទំនិញនាំចេញនិងនាំចូលអោយបានសមស្របនោះ ថ្លៃគិតពន្ធលើទំនិញនាំចេញនិងនាំចូលដែលភ្ជាប់មកជាមួយសេចក្ដីណែនាំលេខ ០០៥ កហវ. ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៨៩ របស់ក្រសួងហិរញ្ញវត្ថុ និងសេចក្ដីណែនាំលេខ ០០៨ សណន.កហវ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៨៩ ស្ដីពីការគិតពន្ធទំនិញរបស់យន្តជំនួញ ត្រូវអស់ប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩០ តទៅ ។

*ប្រការ ២* : ថ្លៃគិតពន្ធលើទំនិញនាំចេញនិងនាំចូល ត្រូវបានកំណត់សាជាថ្មីតាមតារាងភ្ជាប់ជាមួយប្រកាសនេះ នឹងត្រូវបានអនុវត្តចាប់ពីថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩០ តទៅ ។

Downloaded from http://www.khmerlaws.com

*ប្រការ ៣* : ក្នុងរយៈពេលអនុវត្តបើជួបករណីលំបាកស្មុគស្មាញ ឬ ពិនិត្យឃើញថា ថ្លៃគិតពន្ធនេះពុំសមស្របទេនោះ បណ្ដាសាខាទីចាត់ការ និងស្នាក់ការគយ-រដ្ឋាករ ត្រូវរាយការណ៍ជាបន្ទាន់មកទីចាត់ការគយនិងរដ្ឋាករ ដើម្បីស្រាវជ្រាវពិចារណា ដោះស្រាយ អោយបានសមស្រប ។

រដ្ឋមន្ត្រី ក្រសួងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
ឆាយ - ថន

*ភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩០*

# ប្រកាសលេខ ០១១ កហវ

## ស្ដីពីការបន្ធូរបន្ថយប្រាក់ពន្ធលើទំនិញនាំចូល ចំពោះមុខទំនិញដែលជាប់អត្រាពន្ធខ្ពស់

— បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

— បានឃើញច្បាប់ស្ដីពីការកែប្រែខាត់តាំង តួនាទីភារកិច្ចរបស់ក្រសួងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៤៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩

— បានឃើញច្បាប់ស្ដីពីពន្ធលើមុខទំនិញនាំចេញ និងនាំចូល ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩

— បានឃើញសេចក្ដីសំរេចលេខ ១២៩ សសរ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩០ ស្ដីពីការបន្ធូរបន្ថយប្រាក់ពន្ធលើទំនិញនាំចូលចំពោះមុខទំនិញដែលជាប់អត្រាពន្ធខ្ពស់

## កំណត់

*ប្រការ ១* : ដោយយោងទៅតាមសភាពការណ៍បច្ចុប្បន្ន និងទៅតាមថ្លៃលក់ទំនិញនៅលើទីផ្សារ មុខទំនិញនាំចូលមួយចំនួន ត្រូវបានបន្ធូរបន្ថយលើប្រាក់ពន្ធដែលកំណត់ក្នុងតារាងថ្លៃគិតលើទំនិញនាំចូល និងភ្ជាប់ជាមួយប្រកាសលេខ ០១០ កហវ ចុះថ្ងៃទី ០៨ ខែតុលា ឆ្នាំ ១៩៩០ ដូចមានខាងក្រោម :

— បារី ៥៥៥ ផិនហៀល ចាំលីម៉ាស់, ហ្សៀរអេសបេ បន្ថយ ៦៥ ភាគរយលើប្រាក់ពន្ធ

Downloaded from http://www.khmerlaws.com

— បារី ហៀ្សក, ហេរ៉ូ, ហ្វីន ម៉ាលបូរ៉ូ, រុយប៊ី បន្ថយ ៦៨ ភាគរយលើប្រាក់ពន្ធ
— បារីប្រភេទផ្សេង ៗ បន្ថយ ៧០ ភាគរយលើប្រាក់ពន្ធ
— ទូរទស្សន៍ពណ៌ ចាប់ពី ១៨អ៊ិញចុះក្រោម បន្ថយ ៨០ ភាគរយលើប្រាក់ពន្ធ
— ទូរទស្សន៍ពណ៌ចាប់ពី ១៩អ៊ិញដល់២៣ អ៊ិញ បន្ថយ ៨២ ភាគរយលើប្រាក់ពន្ធ
— វីដេអូ « ក្បាលវីឌីអូ » ចាប់ពី ៣ ស៊ីស្តែមចុះក្រោម បន្ថយ៨០ ភាគរយលើប្រាក់ពន្ធ
— វីដេអូ « ក្បាលវីឌីអូ » ចាប់ពី ៤ស៊ីស្តែមឡើង បន្ថយ ៨៣ ភាគរយលើប្រាក់ពន្ធ
— ម៉ាញេចាប់ពី ៣០ វ៉ាត់ចុះក្រោម បន្ថយ ៧៨ ភាគរយលើប្រាក់ពន្ធ
— ម៉ាញេចាប់ពី ៣១ វ៉ាត់ដល់ ៦០ វ៉ាត់ បន្ថយ ៨០ ភាគរយលើប្រាក់ពន្ធ
— ម៉ាញេលើសពី ៦០ វ៉ាត់ដល់ ១០០ វ៉ាត់ បន្ថយ ៨០ ភាគរយលើប្រាក់ពន្ធ
— ស្រាបៀរគ្រប់ប្រភេទ បន្ថយ ៥៦ ភាគរយលើប្រាក់ពន្ធ

*ប្រការ ២* : ការបន្ថយប្រាក់ពន្ធតាមប្រការខាងលើនេះអនុវត្តទៅស្នាក់ការក្រុមពិនិត្យ កំពង់ផែក្រុងកំពង់សោម កំពង់ផែទំនប់រលកក្រុងកំពង់សោម ចាំកខ្លងខេត្ត កោះកុង និងកំពង់ផែភ្នំពេញ ។ ចំពោះស្នាក់ការផ្សេង ៗ ទៀតពុំបានអនុញ្ញាតិអោយអនុវត្ត តាមប្រការ ១ ខាងលើនេះឡើយ ។

*ប្រការ ៣* : ប្រកាសនេះនឹងមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩០ នេះតទៅ ។

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
ទាយ-១៩

Downloaded from http://www.khmerlaws.com

## អន្តរក្រសួង

## ២ - ក្រសួងហិរញ្ញវត្ថុ ធនាគារជាតិកម្ពុជា

## សេចក្តីណែនាំ

*ភ្នំពេញ, ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩០*

## សេចក្តីណែនាំ លេខ ក៩៩០ ០០១សណ ន

## ស្តីពីការធ្វើអាជីវកម្មប្តូរប្រាក់ និងទិញ-លក់ លោហធាតុ-ត្បូងថ្មមានតម្លៃ

អនុលោមតាមសារាចររបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ០៨ សរ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩០ ស្តីពីការគ្រប់គ្រងអាជីវកម្មប្តូរប្រាក់ និងទិញ-លក់លោហធាតុ-ត្បូងថ្មមានតម្លៃ និងសំដៅកែលំអ-គ្រប់គ្រងមុខរបរនេះ ដោយធ្វើសកម្មភាពក្នុងលក្ខណៈស្របច្បាប់មានរបៀបរៀបរយ សណ្តាប់ធ្នាប់សង្គម និងលក្ខណៈបំរើផលប្រយោជន៍សេដ្ឋកិច្ច-សង្គម យ៉ាងពិតប្រាកដនោះ អន្តរក្រសួងហិរញ្ញវត្ថុ ធនាគារជាតិកម្ពុជាសូមធ្វើការណែនាំ ចំពោះអ្នកធ្វើអាជីវកម្មដូចពោលខាងលើ តាមរាល់ចំណុចខាងក្រោមនេះ :

— *អំពីការធ្វើអាជីវកម្មប្តូរប្រាក់*

១.១. អាជីវកម្មប្តូរប្រាក់នេះមានន័យកំណត់សំរាប់មុខរបរទិញ-លក់ ទល់និងប្រាក់រៀលរបស់ជាតិ នូវប្រាក់បរទេសគ្រប់ប្រភេទ ទោះបីដោយប្រើប្រាស់សាច់ប្រាក់ ឬតាមរូបភាពទូទាត់ផ្សេងៗទៀតក្តី ។

១.២. ការធ្វើអាជីវកម្មប្តូរប្រាក់ ក្នុងទិដ្ឋភាពច្របូកច្របល់ ដោយគ្មានច្បាប់អនុញ្ញាតនាំអោយជះឥទ្ធិពលមិនល្អ ដល់តំលៃលើទីផ្សារ និងប៉ះពាល់ដល់របៀបរៀបរយ-សណ្តាប់ធ្នាប់សង្គម ដូចក្នុងរយៈកាលកន្លងមកនេះ ត្រូវតែបញ្ឈប់ជាបន្ទាន់ ដោយឥតលក្ខខណ្ឌ តាមស្មារតីនៃសារាចររបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដូចបានយោងបញ្ជាក់ខាងលើនេះស្រាប់ ។

១.៣. បុគ្គលឬក្រុមបុគ្គលណា ដែលមានបំណងបន្តធ្វើឬធ្វើថ្មី នូវអាជីវកម្មប្តូរប្រាក់ ដោយមានលក្ខណៈស្របច្បាប់ត្រឹមត្រូវ ត្រូវដាក់ពាក្យសុំការអនុញ្ញាត ពីអន្តរក្រសួងហិរញ្ញវត្ថុធនាគារជាតិកម្ពុជា ជាមុន ដោយកំណត់អាស័យដ្ឋានរបស់ហាងឬទីតាំងធ្វើអាជីវកម្ម ព្រមទាំងសាខារបស់ខ្លួន បើសិនជាមាន និងផ្លាកយីហោ ដោយមានចុះឈ្មោះច្បាស់លាស់ បើពុំដូច្នោះទេ សាមីបុគ្គលឬក្រុម

Downloaded from http://www.khmerlaws.com

បុគ្គលដែលចចែសរឹងរូសធ្វើអាជីវកម្មប្តូរប្រាក់ដោយលួចលាក់ នឹងត្រូវទទួលខុសត្រូវចំពោះមុខវាល់វិធានការលុបចំបាត់ទៅវិញ របស់ស្ថាប័នមានសមត្ថកិច្ច តាមបទបញ្ញត្តិជាធរមាន ។

១.៤. អាគារប្តូរប្រាក់ ដែលបានទទួលការអនុញ្ញាត មានសិទ្ធិគ្រប់គ្រាន់ក្នុងការទិញតាមអត្រាសំរុះសំរួលជាមួយអតិថិជនរបស់ខ្លួន នូវរូបិយប័ណ្ណនិងរាល់លិខិតស្នាមមានតម្លៃជារូបិយប័ណ្ណពីសាធារណជនកម្ពុជាឬបរទេស និងមានសិទ្ធិលក់រូបិយប័ណ្ណនិងលិខិតស្នាមទាំងនេះវិញ ទៅអោយធនាគារអាជីវកម្ម ដែលបានទទួលការអនុញ្ញាត ឬអោយធនាគារជាតិកម្ពុជា តាមអត្រាទិញលក់ប្រចាំថ្ងៃ ដែលស្ថាប័ននេះចេញផ្សាយ ក្នុងគ្រានីមួយៗ ដោយមានការឯកភាពជាមួយក្រសួងហិរញ្ញវត្ថុ ។

ម្យ៉ាងទៀត អាគារប្តូរប្រាក់ក៏អាចលក់ប្រាក់ចំណូលជារូបិយប័ណ្ណ ឬលិខិតស្នាមមានតម្លៃជារូបិយប័ណ្ណ អោយសាធារណជនកម្ពុជាឬបរទេសបានដែរ តែត្រូវអនុវត្តតាមបែបបទ និងរបៀបពិធីការ របស់ធនាគារជាតិកម្ពុជា ។

១.៥. ដើម្បីបង្កលក្ខណៈងាយស្រួល ដល់ទំនាក់ទំនងរវាងគ្នា អន្តរក្រសួងហិរញ្ញវត្ថុធនាគារជាតិកម្ពុជានឹងអនុញ្ញាតអោយអាគារប្តូរប្រាក់ ដែលបង្កើតឡើងនីមួយៗ បើកគណនីប្រាក់បញ្ញើនៅធនាគារអាជីវកម្ម ដែលបានទទួលការអនុញ្ញាត សំរាប់សំរួលដល់ការងារទូទាត់និងដល់ការធានាសន្តិសុខអោយសាច់ប្រាក់រូបិយប័ណ្ណ ឬ ប្រាក់រៀល ដែលត្រូវបង់ចូល ។

១.៦ – អាគារប្តូរប្រាក់ ដែលបានទទួលការអនុញ្ញាត ត្រូវអនុវត្តការចេញវិក្កយប័ត្រទិញ – លក់ ប្រចាំថ្ងៃ អោយបានត្រឹមត្រូវបំផុត រាយការណ៍ពីសកម្មភាពទិញ លក់នោះ យ៉ាងទៀងទាត់ទៅរៀងរាល់ចុងសប្តាហ៍ អោយអន្តរក្រសួងហិរញ្ញវត្ថុ – ធនាគារជាតិកម្ពុជា តាមគំរូឯកភាពដែលស្ថាប័នទាំងពីរនឹងចេញផ្សាយ ហើយត្រូវបំពេញភារកិច្ចបង់ពន្ធតាមច្បាប់របស់រដ្ឋ ។

*២ – អំពីការធ្វើអាជីវកម្មទិញ – លក់ លោហធាតុ – ត្បូងថ្មមានតម្លៃ*

២.១ – ឆ្លងកាត់រយៈកាលច្រើនឆ្នាំកន្លងមក ការធ្វើអាជីវកម្មទិញ – លក់ លោហធាតុត្បូងថ្មមានតម្លៃបានប្រព្រឹត្តទៅ ដោយខ្វះការគ្រប់គ្រង ដោយគ្រប់ជ្រុងជ្រោយ ពីសំណាក់ស្ថាប័នជំនាញនិងមានសមត្ថកិច្ចគ្រប់គ្រាន់ ជាប្រការមិនត្រូវទុកអោយកួសបន្ទាយតទៅទៀតបានឡើយព្រោះនាំអោយខូចរបៀបរៀបរយ – សណ្តាប់ធ្នាប់សង្គម និងជះឥទ្ធិពលអាក្រក់ដល់តម្លៃលើទីផ្សារព្រមទាំងធ្វើអោយបាត់បង់ចំណូលថវិការជូនរដ្ឋ មិនប្លែកអ្វីពីផលវិបាកនៃអាជីវកម្មប្តូរប្រាក់នោះដែរ ។

២.២ – អាស្រ័យហេតុនេះ បុគ្គល ឬ ក្រុមបុគ្គល ដែលកំពុងធ្វើអាជីវកម្មទិញ – លក់

Downloaded from http://www.khmerlaws.com

លោហធាតុ - ត្បូងថ្មមានតម្លៃ ទោះបីពុំទាន់មានច្បាប់អនុញ្ញាតឬមានច្បាប់អនុញ្ញាតហើយក្តី និង បុគ្គល ឬ ក្រុមបុគ្គល ដែលមានបំណងចង់ធ្វើអាជីវកម្មប្រភេទខាងលើនេះ សុទ្ធតែត្រូវបានណែនាំ អោយបំពេញរាល់លក្ខខណ្ឌដូចខាងក្រោមនេះ :

២.២.១ — ត្រូវដាក់ពាក្យសុំការអនុញ្ញាតពីអន្តរក្រសួងហិរញ្ញវត្ថុ - ធនាគារជាតិកម្ពុជាក្នុង រយៈពេល ៣០ ថ្ងៃ យ៉ាងយឺតបំផុត ចាប់ពីថ្ងៃចេញផ្សាយជាសាធារណៈនៃសេចក្តីណែនាំនេះ ។

អ្នកដាក់ពាក្យសុំការអនុញ្ញាតត្រូវកំណត់អោយខាងអាស័យដ្ឋាននៃអាគារ ឬទីតាំងធ្វើអាជីវ- កម្ម ព្រមទាំងសាខារបស់ខ្លួន បើសិនជាមាន - ផ្លាកយីហោ - សញ្ញាសំគាល់និងចំនួនប្រាក់ ដើមទុនដែលត្រូវរាយការណ៍ចុះបញ្ជី អោយបានច្បាស់លាស់និងស្មោះត្រង់ត្រឹមត្រូវ ។

អន្តរក្រសួងហិរញ្ញវត្ថុ - ធនាគារជាតិកម្ពុជានឹងរាប់រងអំពីការចេញលិខិតអនុញ្ញាតការណែនាំ អនុវត្ត និងបន្តពិភាក្សាជាមួយសាមីជនអំពីរូបមន្តអត្រាទិញ - លក់ ក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពី រយៈពេលកំណត់ ៣០ ថ្ងៃ ខាងលើនេះ

២.២.២ . ផុតកំណត់រយៈពេល ៤៥ ថ្ងៃយ៉ាងយឺតបំផុត ចាប់ពីពេលផ្សាយជាសាធារណៈ នៃសេចក្តីណែនាំ បុគ្គល ឬ ក្រុមបុគ្គលណា ដែលនៅតែស្រាយពុំបានលិខិតអនុញ្ញាតថ្មី ពីអន្តរ ក្រសួងហិរញ្ញវត្ថុ - ធនាគារជាតិកម្ពុជា ហើយបន្តធ្វើអាជីវកម្មទិញ - លក់ លោហធាតុ-ត្បូងថ្មមាន តម្លៃ តាមលិខិតអនុញ្ញាតចាស់ ឬដោយលួចលាក់ទៀត និងត្រូវទទួលខុសត្រូវចំពោះមុខរាល់ វិធានការត្រួតពិនិត្យឡើងវិញ របស់ស្ថាប័នមានសមត្ថកិច្ច តាមបទបញ្ញត្តិជាធរមាន ។

២.២.៣ - ក្នុងសកម្មភាពរបស់ខ្លួន អាគារទិញ-លោហធាតុ-ត្បូងថ្មមានតម្លៃមានភារកិច្ច :

— អនុវត្តការចេញវិក្កយប័ត្រទិញ- លក់ប្រចាំថ្ងៃ អោយបានត្រឹមត្រូវនឹងស្មោះត្រង់បំផុត

— រាយការណ៍ពីសកម្មភាពទិញ-លក់នោះយ៉ាងទៀងទាត់ រៀងរាល់ចុងសប្តាហ៍ អោយ អន្តរក្រសួងហិរញ្ញវត្ថុ- ធនាគារជាតិកម្ពុជា តាមគំរូឯកសារដែលស្ថាប័នទាំងពីនឹងចេញផ្សាយអោយ ប្រតិបត្តិតាម .

— បំពេញកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ តាមច្បាប់សារពើពន្ធនៃរដ្ឋកម្ពុជា ។

*៣ អំពីការគ្រប់គ្រងសៀវភៅបញ្ជីគណនេយ្យ និងវិក្កយប័ត្រ " ទិញ- លក់ "*

ក្នុងការអនុវត្តន៍ជាបណ្តោះអាសន្ន គ្រប់អាជីវកម្មដែលបានទទួលការអនុញ្ញាតអោយធ្វើ អាជីវកម្មទិញ-លក់ នៅរដ្ឋកម្ពុជា ត្រូវមានកាតព្វកិច្ចកាន់កាប់សៀវភៅបញ្ជីវិក្កយប័ត្រទិញ -លក់ ដូចមានខាងក្រោមនេះ :

Downloaded from http://www.khmerlaws.com

— បណ្ណប្រកាសទុកផ្ទាល់ខ្លួន
— សៀវភៅបញ្ជីប្រចាំថ្ងៃ
— សៀវភៅបេឡាប្រចាំថ្ងៃ
— បណ្ណចំណូល-បណ្ណចំណាយ
— វិក្កយប័ត្រទិញ—លក់

*៣·១ - ការណែនាំអនុវត្តប្រើប្រាស់សៀវភៅបញ្ជី*

— *បណ្ណប្រកាសទុនផ្ទាល់ខ្លួន* : ត្រូវមានការទទួលស្គាល់ ឬការអនុញ្ញាតពីអន្តរក្រសួងហិរញ្ញវត្ថុ-ធនាគារជាតិកម្ពុជា ដែលប្រកាសអោយធ្វើអាជីវកម្ម ។

— *សៀវភៅបញ្ជីតាមដានប្រចាំថ្ងៃ* : ជាបញ្ជីសំណៅ ឬ បញ្ជីកំណត់ដៃ គឺជាបញ្ជីឬសៀវភៅដែលអាជីវករកត់ត្រាជារៀងរាល់ថ្ងៃ និងតាមលំដាប់លំដោយ នូវការប្រតិបត្តិអាជីវកម្មគ្រប់ប្រភេទរបស់ខ្លួន ទ្រព្យសកម្មនិងបំណុលអកម្ម នៃចលនាមូលនិធិ «និយាយអោយខ្លីគឺថ្វីៗទាំងអស់ដែលអាជីវករទទួលបាន និងចំណាយចេញ» ។

— *សៀវភៅបេឡាប្រចាំថ្ងៃ* : ត្រូវកត់ត្រារាល់ចាត់ភាគចំណូល-ចំណាយដែលកើតមានឡើង និងត្រូវធ្វើតុល្យភាពចំណូល ចំណាយជារៀងរាល់ថ្ងៃ ដើម្បីងាយស្រួលក្នុងការតាមដានត្រួតពិនិត្យ ។

— *បណ្ណចំណូល- ចំណាយ*

*ក· បណ្ណចំណូល* : ធ្វើជាសក្ខីប័ត្រចំណូល ចំណូលជាសាច់ប្រាក់ លោហធាតុត្បូងថ្មតម្លៃក្នុងការគ្រប់គ្រងចំណូលបេឡា អោយបានត្រឹមត្រូវ និងធ្វើជាមូលដ្ឋាន ដើម្បីចុះបញ្ជីបេឡា ។ បណ្ណនេះត្រូវសរសេរជា ៣ ច្បាប់ ភ្ជាប់ជាមួយនូវបណ្ណសក្ខីប័ត្រដើម ។

*ខ. បណ្ណចំណាយ* : ធ្វើជាសក្ខីប័ត្រចំណាយ ចំណាយជាសាច់ប្រាក់ លោហធាតុត្បូងថ្មមានតម្លៃ និងធ្វើជាមូលដ្ឋានចុះបញ្ជីបេឡា ។ បណ្ណនេះត្រូវសរសេរជា ៣ ច្បាប់ភ្ជាប់ជាមួយនូវបណ្ណសក្ខីប័ត្រដើម ។

— *វិក្កយប័ត្រទិញ - លក់* : គ្រប់អាជីវករ ដែលបានទទួលការអនុញ្ញាតអោយធ្វើអាជីវកម្មត្រូវបោះពុម្ពគំរូវិក្កយប័ត្រទិញ-លក់ តាមគំរូណែនាំរបស់អន្តរក្រសួង ដែលបានផ្សព្វផ្សាយអោយអនុវត្តតាមចំណុច ១ ង និង ២.២.៣ ខាងលើនេះ ។

ប៉ុន្តែ គំរូវិក្កយប័ត្រទាំងនោះត្រូវតែបានដាក់ជូនធនាគារ ដើម្បីបោះសញ្ញាសំគាល់មុនការអនុញ្ញាតអោយប្រើប្រាស់ ។

Downloaded from http://www.khmerlaws.com

សេចក្តីណែនាំនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ តាមខ្លឹមសារណែនាំ ជនដែលពាក់ព័ន្ធ ឬដែលមានចំណងក្នុងអាជីវកម្មប្តូរប្រាក់ និងទិញ លក់លោហធាតុ-ត្បូងថ្មមានតម្លៃទាំងអស់ អាចប្រាស្រ័យទាក់ទងនិងដាក់ពាក្យសុំលិខិតអនុញ្ញាតនៅធនាគារជាតិកម្ពុជា « នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ » អាគារលេខ ២៦ ផ្លូវលេខ ១១៤ នៅភ្នំពេញ និងនៅតាមធនាគារឯកទេសខេត្ត-ក្រុង ចំពោះអាជីវករប្តូរប្រាក់ទិញ – លក់លោហធាតុត្បូងថ្មមានតម្លៃនៅតាមខេត្ត–ក្រុង រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃផ្សាយជាសាធារណៈរហូតទៅ ។

អន្តរក្រសួង

ហិរញ្ញវត្ថុ – ធនាគារជាតិកម្ពុជា

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ
ហត្ថលេខា និងត្រា
ឆាយ ថន

ប្រធានធនាគារជាតិកម្ពុជា
ហត្ថលេខា និងត្រា
ចា រៀង

Downloaded from http://www.khmerlaws.com

# សូមកែតម្រូវ

## សៀវភៅរដ្ឋកិច្ច លេខ ១០ ខែ តុលា ឆ្នាំ ១៩៩០

| លេខរៀង | ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|---|
| ១ | ២៦៥ | ១ | យុវជន | យុទ្ធជន |
| ២ | ២៦៥ | ៣ | យុវជន | យុទ្ធជន |
| ៣ | ២៦៥ | ១២ | ប្រាក់ឧបត្ថម្ភជី | ប្រាក់ឧបត្ថម្ភ |
| ៤ | ២៧៣ | ២០ | វយកាល | វយៈកាល |
| ៥ | ២៧៥ | ២៣ | បញ្ជិ | បញ្ជី |
| ៦ | ២៧៦ | ៧ | ប្រកាស់ | ប្រកាស |

Downloaded from http://www.khmerlaws.com

សហគ្រាសសម្ព័ន្ធរោងពុម្ព
បោះពុម្ពនៅរោងពុម្ពកាលំម៉ាក្ស
លើកទី ១ ចំនួន ៩.០០០ ច្បាប់

Downloaded from http://www.khmerlaws.com